# កិច្ចប្រជុំប្រចាំឆ្នាំ លើកទី៣១

## ក្រោមប្រធានបទ **សង្គមស៊ីវិលរួមគ្នា សម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅកម្ពុជា**

**ថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០២១**

តាមអនឡាញ តាមស្ទូមខន់ហ្វើរិន *(នឹងផ្តល់ជូនតំណភ្ជាប់តាមក្រោយ)*

## ១- សេចក្តីផ្តើម

គណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា (គ.ស.ក) ជាអង្គការសមាជិកភាពឈានមុខគេ ដែលមានសមាជិកទាំងអង្គការជាតិ និងអង្គការបរទេសនៅកម្ពុជា ហើយបានដើរតួនាទីយ៉ាងសំខាន់ ចាប់តាំងពីឆ្នាំ១៩៩០។ អង្គការ គ.ស.ក មានតួនាទី និងធ្វើកិច្ចការយ៉ាងសកម្មជាងបីទស្សវត្សរ៍ ក្នុងនាមជាអ្នកសម្របសម្រួលឲ្យមានរួបរួមគ្នា ដើម្បីបង្កបរិយាកាសអំណោយផលសម្រាប់អង្គការសង្គមស៊ីវិល អភិបាលកិច្ចស្ថាប័ន និងគណនេយ្យភាព ក្នុងការធ្វើឲ្យប្រសើរឡើងនូវប្រសិទ្ធភាព នៃដំណើរអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ និងប្រកបដោយនិរន្តរភាពនៅកម្ពុជា។ ក្នុងដំណាក់កាលទីបួននៃកម្មវិធីមជ្ឈមណ្ឌលអភិបាលកិច្ច (GHP 2021-2023) ក្រោមទស្សនៈវិស័យ ការអភិវឌ្ឍប្រកបដោយនិរន្តរភាព និងប្រជាធិបតេយ្យសម្រាប់ប្រទេសកម្ពុជា ហើយមានគោលដៅធំពីរ៖១) ការលើកកម្ពស់បរិយាកាសអំណោយផលសម្រាប់អង្គការសង្គមស៊ីវិល និង២) និរន្តរភាព និងដំណើរការធនធានសម្រាប់សង្គមស៊ីវិលនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

ដើម្បីអបអរសាទរនូវតួនាទីយ៉ាងសំខាន់នេះ ជាពិសេសក្នុងការសម្របសម្រួល និងគាំទ្រ សម្រាប់អង្គការសមាជិកភាព និងភាពជាដៃគូ អង្គការ គ.ស.ក នឹងរៀបចំកិច្ចប្រជុំប្រចាំឆ្នាំ ដែលជាព្រឹត្តិការណ៍ចម្បងសម្រាប់សមាជិកភាពដៃគូ និងតួអង្គអភិវឌ្ឍសំខាន់ៗ។ ដោយសារការឆ្លងរាតត្បាតនៃជំងឺកូវីដ១៩ យន្តការការងារមួយចំនួនត្រូវបាន រៀបចំតាមអនឡាញ និងមានការកែសម្រួល ដើម្បីស្របតាមបរិការណ៍។ ស្របតាមលក្ខន្តិកៈ កិច្ចប្រជុំប្រចាំឆ្នាំនេះ នឹងត្រូវបានធ្វើឡើង ដើម្បីពិនិត្យឡើងវិញនូវការងារកន្លងមក ព្រមទាំងពិភាក្សា និងរៀនសូត្រសម្រាប់ផែនការការងារឆ្នាំបន្ទាប់។ សម្រាប់កម្មវិធីឆ្នាំនេះ នឹងប្រារព្ធឡើងតាមអនឡាញ ***នាព្រឹកថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០២១*** ក្រោមប្រធានបទ **សង្គមស៊ីវិលរួមគ្នា សម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅកម្ពុជា** ក្នុងគោលបំណងដើម្បីបង្ហាញពីសាមគ្គីភាព និងបណ្តាញទំនាក់ទំនងការងារ សមិទ្ធផលជោគជ័យរបស់អង្គការសមាជិកភាព និង គ.ស.ក និងផែនការសម្រាប់សហប្រតិបត្តិការទៅអនាគត។

អ្នកចូលរួមប្រមាណជាង ២០០ នាក់ ត្រូវបានអញ្ជើញចូលរួម ជាភ្ញៀវកិត្តិយស មកពីអង្គភាពផ្សេងៗ ដែលជាអង្គការសមាជិកអង្គការ គ.ស.ក ដៃគូសង្គមស៊ីវិល និងភ្នាក់ងារអភិវឌ្ឍន៍ផ្សេងៗ *(តំណាងមន្ត្រីរដ្ឋាភិបាល ម្ចាស់ជំនួយ និងដៃគូអភិវឌ្ឍន៍ តំណាងស្ថាប័នផ្សេងៗ រួមទាំងវិស័យឯកជន)* តំណាងអង្គការសហគមន៍មូលដ្ឋាន និងក្រុមយុវជនជាដើម។

## ២- គោលបំណង

- ឆ្លុះបញ្ចាំងពីសកម្មភាពការងារឆ្នាំកន្លងទៅ និងអបអរសមិទ្ធផលសម្រេចបាន ព្រមទាំងការថ្លែងអំណរគុណពីការចូលរួមចំណែកក្នុងការអភិវឌ្ឍនៅកម្ពុជា
- ទទួលស្គាល់នូវការចូលរួមគាំទ្ររបស់អង្គការសមាជិកភាព និងដៃគូ ក្នុងការលើកកម្ពស់បរិយាកាសសម្រាប់សង្គមស៊ីវិល
- ធ្វើអោយប្រសើរឡើងនូវកិច្ចសហប្រតិបត្តិការក្នុងចំណោមអង្គការសមាជិកភាព ដៃគូអង្គការសម្របសម្រួលខេត្ត ដៃគូអភិវឌ្ឍផ្សេងៗ សម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ ក្នុងការឆ្លើយតបបញ្ហាផ្សេងៗនៃការអភិវឌ្ឍ។

## ៣- សេចក្តីព្រាងរបៀបវារៈ

| ម៉ោង | ប្រធានបទ | វាគ្មិន |
|---|---|---|
| ៨:០០ – ៨:៣០ | **ការចូលរួមតាមអនឡាញ និងទំនាក់ទំនង** | អង្គការ គ.ស.ក និង អ្នកចូលរួម |
| ៨:៣០ – ៨:៤០ | • **ការប្រកាសកម្មវិធី** | កាន់កម្មវិធី៖ **អ្នកស្រី ចាន់ សុម៉ាលី**<br>អង្គការ គ.ស.ក |
| ៨:៤០ – ៨:៥០ | • **របាំជូនពរ** *(តន្ត្រី និងការសំដែងពីចម្ងាយ)* | **អង្គការ Cambodia Living Art**<br>សមាជិក អង្គការ គ.ស.ក |
| ៨:៥០ – ៩:២០ | • **កិច្ចស្វាគមន៍**<br>• **ខ្លឹមសារគន្លឹះ និងចំណាប់អារម្មណ៍ពីដៃគូម្ចាស់ជំនួយ**<br>• **ចំណាប់អារម្មណ៍ និងបើកកម្មវិធីដោយដៃគូរាជរដ្ឋាភិបាល** | ▪ **លោក ហុង វស្ស៊ី** ប្រធានគណៈកម្មាធិការប្រតិបត្តិ និងនាយកប្រចាំប្រទេសអង្គការអាកសិនអេតកម្ពុជា<br>▪ លោក **Franck VIAULT** អគ្គទីប្រឹក្សា-ប្រធានផ្នែកសហប្រតិបត្តិការ នៃសហគមន៍អឺរ៉ុប<br>▪ **ឯកឧត្តម ង៉ាន់ ចំរើន** ប្រធានលេខាធិការដ្ឋាន គ.ជ.អ.ប និងរដ្ឋលេខាធិការក្រសួងមហាផ្ទៃ |
| ៩:២០ – ៩:៥០ | <u>ប្រកាសជាផ្លូវការ</u>៖ **គណៈកម្មាធិការប្រតិបត្តិថ្មី ២០២១-២០២២ និងអំណរគុណគណៈកម្មាធិការ និងនាយកប្រតិបត្តិចប់អាណត្តិ**<br>• សារគន្លឹះពីមេរៀនសំខាន់ៗរបស់គណៈកម្មាធិការប្រតិបត្តិ និងនាយកចប់អាណត្តិ សម្រាប់ការងារជាមួយអង្គការសមាជិកភាព<br>• ចំណាប់អារម្មណ៍ ការតាំងចិត្ត និងសារគន្លឹះយុទ្ធសាស្ត្រការងារជាមួយអង្គការសមាជិក ពីគណៈកម្មាធិការប្រតិបត្តិថ្មី | **អ្នកស្រី ស៊ិន ពុទ្ធារី** នាយិកាប្រតិបត្តិ<br>អង្គការ CCC |

| ៣- សេចក្តីព្រាងរបៀបវារៈ | | |
|---|---|---|
| **ម៉ោង** | **ប្រធានបទ** | **វាគ្មិន** |
| ៩:៥០–១០:២០ | <u>គន្លឹះសំខាន់ៗ</u>៖ **សមិទ្ធិផលសំខាន់ៗ និងហិរញ្ញវត្ថុ សម្រាប់ឆ្នាំ២០២០ និងចក្ខុវិស័យថ្មីឆ្នាំ២០៣០ ព្រមទាំងផែនការប្រតិបត្តិ និងថវិកាឆ្នាំ២០២១៖**<br>• វីដេអូខ្លីពីសមិទ្ធិផលសំខាន់ៗ និងហិរញ្ញវត្ថុឆ្នាំ២០២០<br>• វីដេអូខ្លី និងការបង្ហាញពីចក្ខុវិស័យឆ្នាំ២០៣០ ព្រមទាំងផែនការ និងហិរញ្ញវត្ថុឆ្នាំ២០២១<br><br>**សំណួរ និងចម្លើយ** | ▪ **លោក ច័ន្ទ ភក្តី** ប្រធានប្រតិបត្តិការ និង អភិវឌ្ឍន៍សមាជិកភាព អង្គការ គ.ស.ក<br><br>▪ **លោក នង នាគនរៈ** ប្រធានទំនាក់ទំនង និង អភិវឌ្ឍន៍ធុរៈកិច្ច អង្គការ គ.ស.ក |
| ១០:២០– ១០:៣០ | **សម្រាក ការកម្សាន្ត និងវីដេអូខ្លី** | អ្នកចូលរួមទាំងអស់ |
| ១០:៣០–១១:៤៥ | <u>វេទិកាពិភាក្សារួម</u>៖ **កិច្ចសហការជាយុទ្ធសាស្ត្រ សម្រាប់អង្គការសង្គមស៊ីវិល និងដៃគូ និងថាតើគួរធ្វើយ៉ាងណា ដើម្បីសម្រេចគោលដៅ ក្នុងបរិបទនៃកូវីដ១៩**<br>• តើមានកិច្ចខិតខំប្រឹងប្រែង និងចក្ខុវិស័យរួមអ្វីខ្លះជាយុទ្ធសាស្ត្រ *(ទស្សនៈវិស័យ តួនាទី និងកិច្ចប្រឹងប្រែង)*?<br>• តើមានចំនុចរឹងមាំអ្វីខ្លះសម្រាប់បណ្តាញអង្គការ និងការចូលរួមចំណែកសម្រេចគោលដៅរួមគ្នា?<br>• តើអង្គការសង្គមស៊ីវិល គួរធ្វើយ៉ាងណា ដើម្បីបង្កើនការងាររួមគ្នា ក្នុងភាពជាដៃគូ និងក្នុងបរិបទនៃជំងឺកូវីដ១៩?<br>***យោបល់/សំណូមពរពីបណ្តាញអង្គការខេត្ត និងសមាជិកចូលរួម***<br><br>អ្នកដឹកនាំការពិភាក្សា និងផ្តល់គំនិតសំខាន់ៗពាក់ព័ន្ធកិច្ចសហការ និងភាពជាដៃគូនៃអង្គការ គ ស ក ជាមួយភាគីពាក់ព័ន្ធ។ សក្តានុពល និងយុទ្ធសាស្ត្រផ្សេងៗ ក្នុងការលើកកម្ពស់ភាពជាដៃគូ និងសហការ ក្រោមបរិការណ៍នៃវគ្គពិភាក្សាត្រូវបានចែករំលែកពីវាគ្មិន និងវែកញែកក្នុងវគ្គនេះ។ យុទ្ធសាស្ត្រជារួមសំខាន់ៗត្រូវបានបញ្ជ្រាប និងបន្ត ដើម្បីឈានសម្រេចគោលដៅ។ | **ដឹកនាំការពិភាក្សា៖ លោក ជួប សុខចំរើន**<br>គណៈកម្មាធិការប្រតិបត្តិ នៃអង្គការ គ.ស.ក និងនាយកប្រតិបត្តិអង្គការ ខាណា<br>**គណៈវាគ្មិន៖ វាគ្មិនសំខាន់ៗមកពីអង្គការ បណ្តាញ ដៃគូអភិវឌ្ឍន៍ និងរាជរដ្ឋាភិបាល**<br>- **ឯកឧត្តម** តំណាងលេខាធិការដ្ឋាន គ.ជ.អ.ប *(TBC)*<br>- **អ្នកស្រី Nadia Ottiger**, នាយករងផ្នែកសហប្រតិបត្តិការ-ទីភ្នាក់ងារសម្រាប់ការអភិវឌ្ឍ និងកិច្ចសហប្រតិបត្តិការស្វីស<br>- **អ្នកស្រី Chikako Kodama,** ប្រធានទីប្រឹក្សាបច្ចេកទេសផ្នែកអភិបាលកិច្ច នៃគម្រោងអភិវឌ្ឍន៍អង្គការសហប្រជាជាតិ<br>- **អ្នកស្រី អេង ចាន់ឌី** នាយិការងអង្គការយេនឌ័រ និងអភិវឌ្ឍន៍ដើម្បីកម្ពុជា<br>- **លោក យ៉ត ប៊ុននី** នាយកប្រតិបត្តិអង្គការភាពជាដៃគូអប់រំនៃអង្គការក្រៅរដ្ឋាភិបាល |
| ១១:៤៥– ១២:០០ | **សរុបខ្លឹមសារ និងបិទកម្មវិធី** | **អ្នកស្រី Sandra Veloso** គណៈកម្មាធិការប្រតិបត្តិ និងនាយិកាប្រចាំប្រទេសអង្គការAFSC |

***ចំណាំ៖*** *ក្នុងនាមអ្នករៀបចំ សូមរក្សាសិទ្ធិក្នុងការកែប្រែកម្មវិធីអាស្រ័យលើករណីចាំបាច់របស់វាគ្មិន និងពេលវេលា។ សូមជម្រាបជូនជ្រាបថា៖ សកម្មភាព និងខ្លឹមសារសំខាន់ៗមួយចំនួនរបស់អ្នកចូលរួម នឹងត្រូវបានដកស្រង់ និងចែករំលែកតាមប្រព័ន្ធផ្សព្វផ្សាយដូចជា គេហទំព័រ និងបណ្តាញព័ត៌មានសង្គម។* [http://www.ccc-cambodia.org/en/resources/event-archives](http://www.ccc-cambodia.org/en/resources/event-archives)

[www.facebook.com/CCCsince1990](www.facebook.com/CCCsince1990)
[www.youtube.com/CCCambodia](www.youtube.com/CCCambodia)